**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១២៣៧ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២៤/១៣០៩ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៤ ស្តីពីគោរមងារឧកញ៉ា
- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់ ក្នុងគោលបំណងដើម្បីធានាឱ្យមានឯកសណ្ឋានភាព ការលើកទឹកចិត្ត និងការពង្រឹងការទទួលខុសត្រូវក្នុងការអនុវត្តការងារផ្នែកសង្គមកិច្ច ការលើកតម្កើងកិត្តិយស សីលធម៌ គុណតម្លៃ និងសេចក្តីថ្លៃថ្នូរនៃគោរមងារឧកញ៉ា។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគោរមវន្តតាមលំដាប់ថ្នាក់ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់

**មាត្រា៣ .-**

ឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់ មាន២ប្រភេទ ដូចខាងក្រោម៖

១- ឯកសណ្ឋានផ្លូវការប្រភេទ១។

២- ឯកសណ្ឋានផ្លូវការប្រភេទ២។

### ផ្នែកទី១
### ឯកសណ្ឋានផ្លូវការប្រភេទ១

**មាត្រា៤ .-**

ឯកសណ្ឋានផ្លូវការប្រភេទ១ រួមមានឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់។

**មាត្រា៥ .-**

ឯកសណ្ឋាននៃឯកសណ្ឋានផ្លូវការប្រភេទ១របស់គោរមវន្ត ត្រូវបានកំណត់ដូចខាងក្រោម៖

**១- ឯកសណ្ឋានគោរមវន្តបុរស**

ក- **អាវ៖**

- អាវកុត កតាំង ដៃវែង ពណ៌កាកអំពៅស្រាល ផែកខ្នងខាងក្រោមទាំងសងខាង មានឡេវមុខពណ៌មាសផុសចំនួន៥គ្រាប់ មានហោប៉ៅកាត់លើទ្រូងខាងឆ្វេងចំនួន១ និងហោប៉ៅប៉ះមានគម្របរាងស្លឹកពោធិ៍ខាងក្រោមសងខាង ចោះរន្ធដាក់ឡេវពណ៌មាសផុសចំកណ្តាល
- ចុងដៃអាវផែកទាំងសងខាង មានឡេវចំនួន៤គ្រាប់ ត្រង់ជួរគ្នា
- នៅលើស្មាអាវមានខ្សែរន្ធសងខាងធ្វើពីក្រណាត់ ដែលនៅម្ខាងៗមានរន្ធចំនួន២ សម្រាប់បំពាក់សក្តិលើស្មា។

ខ- **ខោ៖**

- ខោជើងវែងត្រង់ ពណ៌កាកអំពៅស្រាល
- ដេរច្នេះបង្កប់ ចង្កេះត ក្បាលខោវែងស្រួចប្រវែង ៥,៥សង់ទីម៉ែត្រ ជីបក្លីខាងមុខម្ខាងមួយ និងមានហោប៉ៅចំនួន៣
- ហោប៉ៅចំហៀង២ មានមាត់បញ្ចិត
- ហោប៉ៅកាត់ខាងក្រោយ១ នៅផ្នែកខាងស្តាំដេរបង្កប់មិនមានគម្រប។

គ- **ស្បែកជើងនិងស្រោមជើង៖**

- ស្បែកជើងឃ្លុប កខ្លី ស្បែកពណ៌ខ្មៅ កែងកម្ពស់ ៣សង់ទីម៉ែត្រឬកែងរាបស្មើ
- ស្រោមជើងពាក់កណ្តាលស្មងជើង ពណ៌ខ្មៅ។

គំរូឯកសណ្ឋាននៃឯកសណ្ឋានផ្លូវការប្រភេទ១របស់គោរមវន្តបុរស ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

**២- ឯកសណ្ឋានគោរមវន្តនារី**

ក- អាវ៖

-អាវកបើក ដៃវែង ពណ៌កាកអំពៅស្រាល ផែកខ្នងខាងក្រោមមួយចំកណ្តាល មានជីបរាងខ្នងមកក្រោមតាមលក្ខណៈអាវនារី មានឡេវមុខពណ៌មាសផុសចំនួន៥គ្រាប់ និងមានហោប៉ៅខាងមុខដេរបង្កប់ចំនួន២ នៅខាងក្រោមខិតចំហៀងចំចង្កេះទាំងសងខាង ដែលហោប៉ៅម្ខាងៗមានគម្របរាងស្លឹកពោធិ៍ខាងក្រោម ចោះរន្ធដាក់ឡេវពណ៌មាសផុសចំកណ្តាល

-នៅចុងដៃអាវផែកទាំងសងខាង មានឡេវចំនួន៣គ្រាប់ ត្រង់ជួរគ្នា

-នៅលើស្មាអាវមានខ្សែរន្ធសងខាងធ្វើពីក្រណាត់ ដែលនៅម្ខាងៗមានរន្ធចំនួន២ សម្រាប់បំពាក់សក្តិលើស្មា។

**ខ- សំពត់បត់៖**

-សំពត់បត់ ពណ៌កាកអំពៅស្រាល

-សម្រុងត្រឹមភ្នែកគោរ។

**គ- ស្បែកជើង និងស្រោមជើង៖**

-ស្បែកជើងកែងចោត កខ្លី ស្បែកពណ៌ខ្មៅ កែងកម្ពស់ ៥សង់ទីម៉ែត្រ ឬកែងរាបស្មើ

-ស្រោមជើងកខ្លី ពណ៌ខ្មៅ។

គំរូឯកសណ្ឋាននៃឯកសណ្ឋានផ្លូវការប្រភេទ១របស់គោរមវន្តនារី ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា៦ .-**

សញ្ញាសក្តិគោរមវន្តតាមលំដាប់ថ្នាក់សម្រាប់ពាក់លើស្មាទាំងសងខាងនៃឯកសណ្ឋានផ្លូវការប្រភេទ១ ត្រូវបានកំណត់ដូចខាងក្រោម៖

**១- សញ្ញាសក្តិលោកអ្នកឧកញ៉ា៖**

- មានទំហំ ៦សង់ទីម៉ែត្រ គុណនឹង ១៣សង់ទីម៉ែត្រ នៅតាមជាយមានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញសក្តិ ដោយផ្ទៃពណ៌ជីលែង

- មានរូបព្រះរាជសង្ហារមួយពណ៌មាសនៅចំពីលើកំពូលចុងសក្តិ និងគ្រាប់រង្វង់បង្កប់ដោយស្រះ(ឡ) ពេញតួ មានក្បាលស្រះជារូបក្បាលហង្ស ហើយតួស្រះពត់ពេនដោយក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសពណ៌មាសរាងជាស្លឹកពោធិ៍ចំនួន៣គ្រាប់ នៅចំកណ្តាលផ្តើមចេញពីទំហំតូច មធ្យម និងធំ បន្តពីរូបព្រះរាជសង្ហារ

- នៅពីក្រោមគ្រាប់រង្វង់ទំហំធំមានសរសេរអក្សរថា លោកអ្នកឧកញ៉ា ពណ៌មាស ទ្រពីក្រោមដោយក្បាច់ភ្ញីទេសពណ៌មាសសម្រាប់សម្គាល់គោរមងារលោកអ្នកឧកញ៉ា។

**២- សញ្ញាសក្តិអ្នកឧកញ៉ា៖**

- មានទំហំ ៦សង់ទីម៉ែត្រ គុណនឹង ១៣សង់ទីម៉ែត្រ នៅតាមជាយមានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញសក្តិ ដោយផ្ទៃពណ៌បៃតង

- មានរូបព្រះរាជសង្ហារមួយពណ៌មាសនៅចំពីលើកំពូលចុងសក្តិ និងគ្រាប់រង្វង់បង្កប់ដោយស្រះ(ឡ) ពេញតួ មានក្បាលស្រះជារូបក្បាលហង្ស ហើយតួស្រះពត់ពេនដោយក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសពណ៌មាសរាងជាស្លឹកពោធិ៍ចំនួន២គ្រាប់ នៅចំកណ្តាលផ្តើមចេញពីទំហំតូចនិងធំ បន្តពីរូបព្រះរាជសង្ហារ

- នៅពីក្រោមគ្រាប់វង្វង់ទំហំធំមានសរសេរអក្សរថា អ្នកឧកញ៉ា ពណ៌មាស ទ្រពីក្រោមដោយក្បាច់ភ្ញីទេសពណ៌មាសសម្រាប់សម្គាល់គោរមងារអ្នកឧកញ៉ា។

៣- សញ្ញាសក្តិឧកញ៉ា៖

- មានទំហំ ៦សង់ទីម៉ែត្រ គុណនឹង ១៣សង់ទីម៉ែត្រ នៅតាមជាយមានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញសក្តិ ដោយផ្ទៃពណ៌ខៀវចាស់
- មានរូបព្រះរាជសង្ហារមួយពណ៌មាសនៅចំពីលើកំពូលចុងសក្តិ និងគ្រាប់វង្វង់បង្គប់ដោយស្រះ(ឱ) ពេញតួ មានក្បាលស្រះជារូបក្បាលហង្ស ហើយតួស្រះពត់ពេនដោយក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសពណ៌មាសរាងជាស្លឹកពោធិ៍ចំនួន១គ្រាប់ នៅចំកណ្តាលបន្តពីរូបព្រះរាជសង្ហារ
- នៅពីក្រោមគ្រាប់វង្វង់មានសរសេរអក្សរថា ឧកញ៉ា ពណ៌មាស ទ្រពីក្រោមដោយក្បាច់ភ្ញីទេសពណ៌មាសសម្រាប់សម្គាល់គោរមងារឧកញ៉ា។

គំរូសញ្ញាសក្តិគោរមវន្តតាមលំដាប់ថ្នាក់សម្រាប់ពាក់លើស្មាទាំងសងខាងនៃឯកសណ្ឋានផ្លូវការប្រភេទ១ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ។

**មាត្រា៧ .-**

សញ្ញាសម្គាល់គោរមវន្តតាមលំដាប់ថ្នាក់នៃឯកសណ្ឋានផ្លូវការប្រភេទ១ ត្រូវបានកំណត់ដូចខាងក្រោម៖

**១- សញ្ញាសម្គាល់ចុងកអាវ**

សញ្ញាសម្គាល់ចុងកអាវ កតាំងសម្រាប់បុរស និងចុងកអាវ កបើកសម្រាប់នារី មាននិមិត្តសញ្ញាសម្គាល់ដែលមានរំលេចចេញជាស្រះ(ឱ)ពេញតួ មានក្បាលស្រះជារូបក្បាលហង្ស ហើយតួស្រះពត់ពេនដោយក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសពណ៌មាសរាងជាស្លឹកពោធិ៍ទំហំខ្នាត ២,៦សង់ទីម៉ែត្រ គុណនឹង ៣,៥សង់ទីម៉ែត្រ កម្រាស់ ០,៣សង់ទីម៉ែត្រ។

**២- សញ្ញាសម្គាល់គ្រាប់ឡេវ**

គ្រាប់ឡេវមានរាងជាវង្វង់មានស្រះ(ឱ)ពេញតួនៅចំកណ្តាល ដែលមានក្បាលស្រះជារូបក្បាលហង្ស ហើយតួស្រះពត់ពេនដោយក្បាច់ភ្ញីទេសពណ៌មាសផុសនៅចំកណ្តាលផ្ទៃវង្វង់ឡេវពណ៌មាស។ គ្រាប់ឡេវត្រូវបានបែងចែកជា២ខ្នាត ដែលមានទំហំអង្កត់ផ្ចិតដូចខាងក្រោម៖

- គ្រាប់ឡេវតូច ទំហំ ១,៥សង់ទីម៉ែត្រ កម្រាស់ ០,១សង់ទីម៉ែត្រ សម្រាប់ចុងដៃអាវ បញ្ឈរជាជួរត្រង់គ្នាចំនួន៤គ្រាប់ សម្រាប់គោរមវន្តបុរស និងចំនួន៣គ្រាប់ សម្រាប់គោរមវន្តនារី
- គ្រាប់ឡេវធំ ទំហំ ២សង់ទីម៉ែត្រ កម្រាស់ ០,២សង់ទីម៉ែត្រ សម្រាប់ឡេវមុខ បញ្ឈរជាជួរត្រង់គ្នាចំនួន៥គ្រាប់ និងគម្របហោប៉ៅចំនួន២គ្រាប់ សម្រាប់គោរមវន្តបុរសនិងនារី។

គំរូសញ្ញាសម្គាល់គោរមវន្តតាមលំដាប់ថ្នាក់នៃឯកសណ្ឋានផ្លូវការប្រភេទ១ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យនេះ។

## ផ្នែកទី២
## ឯកសណ្ឋានផ្លូវការប្រភេទ២

**មាត្រា៨ .-**

ឯកសណ្ឋានផ្លូវការប្រភេទ២ រួមមានឯកសណ្ឋាន និងសញ្ញាសម្គាល់។

**មាត្រា៩ .-**

ឯកសណ្ឋាននៃឯកសណ្ឋានផ្លូវការប្រភេទ២របស់គោរមវន្តគ្រប់លំដាប់ថ្នាក់ ត្រូវបានកំណត់ដូចខាងក្រោម៖

**១- ឯកសណ្ឋានគោរមវន្តបុរស**

ក- អាវ៖

- អាវធំ កវែងបើក ដៃវែង ពណ៌ខៀវចាស់ ដែលមានលេខកូដ ៨២៨ ប្រើប្រាស់ក្រណាត់រោមចៀម មានឡេវចំនួន២គ្រាប់ មានហោប៉ៅកាត់លើទ្រូងខាងឆ្វេងចំនួន១ និងមានហោប៉ៅមានគម្របសងខាងនៅផ្នែកខាងក្រោម
- នៅចុងដៃអាវទាំងសងខាង មានឡេវចំនួន៤គ្រាប់ ត្រង់ជួរគ្នា។

ខ- ខោ៖

- ខោជើងវែងត្រង់ ពណ៌ខៀវចាស់ ដែលមានលេខកូដ ៨២៨
- ដេរថ្នេរបង្កប់ ចង្កេះត ក្បាលខោវែងស្រួចប្រវែង ៥,៥សង់ទីម៉ែត្រ ជីបភ្លីខាងមុខម្ខាងមួយ និងមានហោប៉ៅចំនួន៤
- ហោប៉ៅចំហៀង២ មានមាត់បញ្ឆិត
- ហោប៉ៅកាត់ខាងក្រោយ២ នៅសងខាងដេរបង្កប់ មិនមានគម្រប។

គ- ស្បែកជើង និងស្រោមជើង៖

- ស្បែកជើងឃ្លុប កខ្លី ស្បែកពណ៌ខ្មៅ កែងកម្ពស់៣សង់ទីម៉ែត្រឬកែងរាបស្មើ
- ស្រោមជើងពាក់កណ្ដាលស្មងជើង ពណ៌ខ្មៅ។

គំរូឯកសណ្ឋាននៃឯកសណ្ឋានផ្លូវការប្រភេទ២របស់គោរមវន្តបុរស ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៥ នៃអនុក្រឹត្យនេះ។

**២- ឯកសណ្ឋានគោរមវន្តនារី**

ក- អាវ៖

- អាវកតាំង បើកចំហមុខបន្តិច ដៃវែង ពណ៌ខៀវចាស់ ប្រើប្រាស់ក្រណាត់ផាមួង ដែលមានក្បាច់ប៉ាក់ផ្កាបង្គុំមួយជុំក មានឡេវបញ្ឆោតចំនួន៥គ្រាប់ពីលើក្បាច់ប៉ាក់បញ្ឈរចំពីមុខ និងមានប្រើខ្សែរូតបង្កប់ពីខាងខ្នង
- នៅលើគល់ស្មាអាវមានប៉ោងបន្តិច និងចុងតួអាវត្រង់ចង្កេះមានរាងប៉ោងក្នុងទម្រង់កន្ទុយប្រា
- នៅចុងដៃអាវទាំងសងខាងមានក្បាច់ប៉ាក់ផ្កាបង្គុំមួយជុំដៃអាវ។

ខ- សំពត់បត់៖

- សំពត់បត់ ពណ៌ខៀវចាស់ ប្រើប្រាស់ក្រណាត់ផាមួង និងមានក្បាច់នៅចុងជាយសំពត់ក្នុងទម្រង់ជាផ្កាបង្គុំមួយជុំ
- សម្រុងត្រឹមភ្នែកគោរ។

គ- ស្បែកជើង និងស្រោមជើង៖

- ស្បែកជើងកែងចោត កខ្លី ស្បែកពណ៌ខ្មៅ កែងកម្ពស់៥សង់ទីម៉ែត្រឬកែងរាបស្មើ
- ស្រោមជើងកខ្លី ពណ៌ខ្មៅ ។

គំរូឯកសណ្ឋាននៃឯកសណ្ឋានផ្លូវការប្រភេទ២របស់គោរមវន្តនារី ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៦ នៃអនុក្រឹត្យនេះ។

**មាត្រា១០.-**

សញ្ញាសម្គាល់គោរមវន្តតាមលំដាប់ថ្នាក់នៃឯកសណ្ឋានផ្លូវការប្រភេទ២ ត្រូវបានកំណត់ដូចខាងក្រោមៈ

**១- សញ្ញាសម្គាល់គោរមវន្តបុរស**

**ក- សញ្ញាសម្គាល់ផ្ទៃខាងក្នុងផ្នែកខាងឆ្វេង**

នៅផ្ទៃខាងក្នុងផ្នែកខាងឆ្វេងនៃតួអាវមានប៉ាក់និមិត្តសញ្ញាសម្គាល់សមាគមឧកញ៉ាកម្ពុជា ទំហំ ៦សង់ទីម៉ែត្រ គុណនឹង ៩សង់ទីម៉ែត្រ និងឈ្មោះរបស់សាមីខ្លួនជាអក្សរឡាតាំង។

**ខ- សញ្ញាសម្គាល់គ្រាប់ឡេវ**

គ្រាប់ឡេវពណ៌ខៀវចាស់ មានរាងជារង្វង់ ដែលមាននិមិត្តសញ្ញាសម្គាល់ពាក្យឧកញ៉ាជាអក្សរឡាតាំងថា OKNHA ផ្នែកខាងលើនៃគ្រាប់ឡេវ និងអក្សរកាត់ជាភាសាអង់គ្លេសថា COA ផ្នែកខាងក្រោមនៃគ្រាប់ឡេវ។

គ្រាប់ឡេវត្រូវបានបែងចែងជា២ខ្នាត ដែលមានទំហំអង្កត់ផ្ចិត ដូចខាងក្រោមៈ

- គ្រាប់ឡេវតូច ទំហំ ១,៥សង់ទីម៉ែត្រ កម្រាស់ ០,២សង់ទីម៉ែត្រ សម្រាប់ចុងដៃអាវ បញ្ឈរជាជួរត្រង់គ្នាចំនួន៤គ្រាប់
- គ្រាប់ឡេវធំ ទំហំ ២សង់ទីម៉ែត្រ កម្រាស់ ០,២៥សង់ទីម៉ែត្រ សម្រាប់ឡេវមុខ បញ្ឈរជាជួរត្រង់គ្នាចំនួន២គ្រាប់។

**គ- សញ្ញាសម្គាល់កន្លាស់អាវ**

កន្លាស់អាវជានិមិត្តសញ្ញាសមាគមឧកញ៉ាកម្ពុជា ទំហំ ៣សង់ទីម៉ែត្រ គុណនឹង ៤សង់ទីម៉ែត្រ កម្រាស់ ០,២៥សង់ទីម៉ែត្រ សម្រាប់ខ្ទាស់នៅលើអាវខាងឆ្វេង ធ្វើពីមាស១៨K។

**២- សញ្ញាសម្គាល់គោរមវន្តនារី**

**ក- សញ្ញាសម្គាល់ចុងកអាវ**

សញ្ញាសម្គាល់ចុងកអាវ កតាំង បើកចំហបន្តិច មានក្បាច់ប៉ាក់ផ្កាបង្ហឹ កម្ពស់ ៥សង់ទីម៉ែត្រ មួយជុំក។

**ខ- សញ្ញាសម្គាល់ចុងដៃអាវ**

សញ្ញាសម្គាល់ចុងដៃអាវមានក្បាច់ប៉ាក់ផ្កាបង្ហឹ កម្ពស់ ៧សង់ទីម៉ែត្រ មួយជុំដៃអាវ។

**គ- សញ្ញាសម្គាល់ក្បាច់ជួរបញ្ឈរចំពីមុខត្រង់កន្លែងដាក់ឡេវ**

សញ្ញាសម្គាល់ត្រង់កន្លែងដាក់ឡេវមានក្បាច់ប៉ាក់បញ្ឈរទម្រង់ផ្កាបង្ហឹកម្ពស់ពេញមួយជំហរអាវពីលើដល់ក្រោម។

**ឃ- សញ្ញាសម្គាល់ចុងសំពត់**

សញ្ញាសម្គាល់ចុងសំពត់ មានក្បាច់ប៉ាក់ផ្កាបង្ហឹកម្ពស់ ២០សង់ទីម៉ែត្រ មួយជុំសំពត់។

**ង- សញ្ញាសម្គាល់គ្រាប់ឡេវ**

គ្រាប់ឡេវបញ្ចោតពីលើក្បាច់ប៉ាក់បញ្ឈរចំពីមុខ មានរាងជារង្វង់មានស្រះ(ឧ)ពេញតួនៅចំកណ្តាលទំហំ ១,៥សង់ទីម៉ែត្រ កម្រាស់ ០,១សង់ទីម៉ែត្រ ចំនួន៥គ្រាប់ ដែលមានក្បាលស្រះជារូបក្បាលហង្ស ហើយតួស្រះពត់ពេនដោយក្បាច់ភ្ញីទេសពណ៌មាស។

ច- សញ្ញាសម្គាល់កន្លាស់អាវ

កន្លាស់អាវជានិមិត្តសញ្ញាសមាគមឧកញ៉ាកម្ពុជា ទំហំ ៣សង់ទីម៉ែត្រ គុណនឹង ៤សង់ទីម៉ែត្រ កម្រាស់ ០,២៥សង់ទីម៉ែត្រ សម្រាប់ខ្ទាស់នៅលើអាវខាងឆ្វេង ធ្វើពីមាស១៨K។

គំរូសញ្ញាសម្គាល់នៃឯកសណ្ឋានផ្លូវការប្រភេទ២ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៧នៃអនុក្រឹត្យនេះ។

## ជំពូកទី៣

## ការគ្រប់គ្រង ការចាត់ចែង និងការប្រើឯកសណ្ឋានផ្លូវការប្រភេទនីមួយៗ របស់គោរមវន្តតាមលំដាប់ថ្នាក់

**មាត្រា១១ .-**

ឯកសណ្ឋានផ្លូវការប្រភេទនីមួយៗរបស់គោរមវន្តតាមលំដាប់ថ្នាក់ ត្រូវរៀបចំ ចាត់ចែង បែងចែក និង គ្រប់គ្រងដោយសមាគមឧកញ៉ាកម្ពុជា ដែលជាដៃគូរបស់រាជរដ្ឋាភិបាល ដូចមានកំណត់ក្នុងមាត្រា១៤ នៃ ព្រះរាជក្រឹត្យលេខ នស/រកត/១០២៤/១៣០៩ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៤ ស្តីពីគោរមងារឧកញ៉ា។

គោរមវន្តតាមលំដាប់ថ្នាក់គ្រប់រូប ត្រូវដាក់ពាក្យស្នើសុំឯកសណ្ឋានផ្លូវការមកសមាគមឧកញ៉ាកម្ពុជា។

**មាត្រា១២ .-**

គោរមវន្តតាមលំដាប់ថ្នាក់ ត្រូវស្លៀកពាក់ឯកសណ្ឋានផ្លូវការប្រភេទនីមួយៗ ដូចមានកំណត់ខាងក្រោមៈ

១- ឯកសណ្ឋានផ្លូវការប្រភេទ១ ប្រើសម្រាប់គោរមវន្តទាំងអស់ស្លៀកពាក់ក្នុងពេលចូលរួមពិធីបុណ្យជាតិ ពិធីបុណ្យប្រពៃណីជាតិ និងពិធីផ្លូវការផ្សេងៗ។

២- ឯកសណ្ឋានផ្លូវការប្រភេទ២ ប្រើសម្រាប់គោរមវន្តជាសមាជិកសមាគមឧកញ៉ាកម្ពុជា ស្លៀកពាក់ ក្នុងពេលចូលរួមពិធីផ្លូវការផ្សេងៗរបស់សមាគមឧកញ៉ាកម្ពុជា។

គោរមវន្តជាសមាជិកសមាគមឧកញ៉ាកម្ពុជា អាចប្រើកន្លាស់អាវនិមិត្តសញ្ញាសមាគមឧកញ៉ាកម្ពុជា ធ្វើពីមាស១៨K ខ្ទាស់នៅលើអាវខាងឆ្វេង នៃឯកសណ្ឋានផ្លូវការប្រភេទ១។

គំរូស្លៀកពាក់ឯកសណ្ឋានផ្លូវការប្រភេទ១ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៨នៃអនុក្រឹត្យនេះ។

គំរូស្លៀកពាក់ឯកសណ្ឋានផ្លូវការប្រភេទ២ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៩នៃអនុក្រឹត្យនេះ។

## ជំពូកទី៤

## ទណ្ឌកម្ម

**មាត្រា១៣ .-**

ជនណាដែលក្លែងឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់ ឬក្លែងបន្លំដោយស្លៀកពាក់ជាសាធារណៈ ដោយគ្មានសិទ្ធិស្លៀកពាក់នូវឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់របស់គោរមវន្ត ដូចមានកំណត់ក្នុង អនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មតាមច្បាប់ជាធរមាន។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា១៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១០កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២៦
ស្តីពីឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់

**គំរូឯកសណ្ឋាននៃឯកសណ្ឋានផ្លូវការប្រភេទ១របស់គោរមវន្តបុរស**


អាវពីមុខ


អាវពីក្រោយ




ខោពីមុខ


ខោពីក្រោយ


ស្រោមជើង


ស្បែកជើង

ឧបសម្ព័ន្ធទី២នៃអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២៦
ស្តីពីឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់

## គំរូឯកសណ្ឋាននៃឯកសណ្ឋានផ្លូវការប្រភេទ១របស់គោរមវន្តនារី



អាវពីមុខ



អាវពីក្រោយ





សំពត់ពីមុខ



សំពត់ពីក្រោយ



ស្រោមជើង



ស្បែកជើង

ឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២៦
ស្តីពីឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់

**គំរូសញ្ញាសក្តិគោរមវន្តតាមលំដាប់ថ្នាក់សម្រាប់ពាក់លើស្មាទាំងសងខាង នៃឯកសណ្ឋានផ្លូវការប្រភេទ១**




លោកអ្នកឧកញ៉ា




អ្នកឧកញ៉ា




ឧកញ៉ា

ឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២៦
ស្តីពីឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់

**គំរូសញ្ញាសម្គាល់គោរមវន្តតាមលំដាប់ថ្នាក់នៃឯកសណ្ឋានផ្លូវការប្រភេទ១**




សញ្ញាសម្គាល់ចុងកអាវ




គ្រាប់ឡេវធំ




គ្រាប់ឡេវតូច

ឧបសម្ព័ន្ធទី៥នៃអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០២៦
ស្តីពីឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់

**គំរូឯកសណ្ឋាននៃឯកសណ្ឋានផ្លូវការប្រភេទ២របស់គោរមវន្តបុរស**



អាវពីមុខ



អាវពីក្រោយ



ផ្ទៃខាងក្នុងផ្នែកខាងឆ្វេង



ខោពីមុខ



ខោពីក្រោយ



ស្រោមជើង



ស្បែកជើង

ឧបសម្ព័ន្ធទី៦នៃអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២៦
ស្ដីពីឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់

**គំរូឯកសណ្ឋាននៃឯកសណ្ឋានផ្លូវការប្រភេទ២របស់គោរមវន្តនារី**



អាវពីមុខ



អាវពីក្រោយ



ស្រោមជើង



សំពត់ពីមុខ



សំពត់ពីក្រោយ



ស្បែកជើង

ឧបសម្ព័ន្ធទី៧នៃអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២៦
ស្ដីពីឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់

## គំរូសញ្ញាសម្គាល់នៃឯកសណ្ឋានផ្លូវការប្រភេទ២

### ១.សញ្ញាសម្គាល់គោរមវន្តបុរស



ផ្ទៃខាងក្នុងផ្នែកខាងធ្វេង



គ្រាប់ឡេវតូច



គ្រាប់ឡេវធំ



សញ្ញាសម្គាល់កន្លាស់អាវ

### ២.សញ្ញាសម្គាល់គោរមវន្តនារី


គំរូក្បាច់



គ្រាប់ឡេវតូច



សញ្ញាសម្គាល់កន្លាស់អាវ


ក្បាច់ចុងកអាវ


ក្បាច់ប៉ាក់បញ្ឈរចំពីមុខ


ក្បាច់ចុងដៃអាវ


ក្បាច់ចុងសំពត់

ឧបសម្ព័ន្ធទី៨នៃអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២៦
ស្តីពីឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់

**គំរូស្លៀកពាក់ឯកសណ្ឋានផ្លូវការប្រភេទ១**

**១.គោរមវន្តបុរស**



លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា

## ២.គោរមងន្តនារី



លោកអ្នកឧកញ៉ា



អ្នកឧកញ៉ា



ឧកញ៉ា

ឧបសម្ព័ន្ធទី៩នៃអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២៦
ស្តីពីឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់

**គំរូស្លៀកពាក់ឯកសណ្ឋានផ្លូវការប្រភេទ២**



គោរមវន្តបុរស គោរមវន្តនារី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥២៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដាក់ឱ្យចូលនិវត្តន៍មន្ត្រីនគរបាលជាតិកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញក្រឹត្យលេខ ១០ក្រ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្មចំពោះនគរបាលប្រជាជនកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១០/៤៦៤ ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣៥ នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៧៨អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតអគ្គនាយកដ្ឋានជនជានមនុស្ស ចំណុះក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ



ទ

## សម្រេច

**មាត្រា១ .—**

ត្រូវបានដាក់ឱ្យចូលនិវត្តន៍នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ១១រូប ដូចមានរាយនាមខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| ១- | វរសេនីយ៍ឯក | **រស់** | **ម៉ិច** | អត្តលេខ | ០១៦៦១ |
| ២- | វរសេនីយ៍ឯក | **លន់** | **មុនីរ័ត្ន** | អត្តលេខ | ០២៤០៦ |
| ៣- | វរសេនីយ៍ឯក | **ហ៊ូ** | **តារា** | អត្តលេខ | ០៣៤៩៥ |
| ៤- | វរសេនីយ៍ឯក | **អ៊ិន** | **អាន** | អត្តលេខ | ១០៨៦៩ |
| ៥- | វរសេនីយ៍ឯក | **ម៉េង** | **សុខុម** | អត្តលេខ | ១១០៧៧ |
| ៦- | វរសេនីយ៍ឯក | **ឡុង** | **សំណាង** | អត្តលេខ | ១២២៧៣ |
| ៧- | វរសេនីយ៍ឯក | **ហ៊ឹម** | **សុវណ្ណារិទ្ធ** | អត្តលេខ | ១៤៣៩៥ |
| ៨- | វរសេនីយ៍ឯក | **ប៊ុក** | **សាលីន** | អត្តលេខ | ៣០៥៩០ |
| ៩- | វរសេនីយ៍ឯក | **សែ** | **ឧត្តរា** | អត្តលេខ | ០៦៤១៤ |
| ១០- | វរសេនីយ៍ឯក | **ខ៊ូវ** | **ត័ណ្ណា** | អត្តលេខ | ៣៣០៩២ |
| ១១- | វរសេនីយ៍ឯក | **នុត** | **សោត័ណា** | អត្តលេខ | ៨៧៥៥២។ |

**មាត្រា២ .—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃអង្គារ ២ កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥២៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ .-**

ត្រូវបានតែងតាំងមុខតំណែងឧត្តមសេនីយ៍ទោ **ឈុន ចន្ណា** អត្តលេខ ៦៣៣១៥ ប្រធាននាយកដ្ឋានគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ។

**មាត្រា២ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ២ កើត ខែបឋមាសាឍឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ៥២៦ អនក្រ.តត**

## អនុក្រឹត្យ

## ស្តីពី

## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ .-**

ត្រូវបានប្រគល់ភារកិច្ចជូនលោកស្រី **លុយ ចំន្ទម៉ាឡែន** អត្តលេខ ២៨៧១២០០០៤៧ ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ២ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ជាប្រធាននាយកដ្ឋានគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា ចំណុះអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ។

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ២ កើត ខែបឋមាសាឍឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥២៧...អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការដាក់ឱ្យចូលនិវត្តន៍មុនពេលកំណត់មន្ត្រីនគរបាលជាតិកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញក្រឹត្យលេខ ១០ក្រ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្មចំពោះនគរបាលប្រជាជនកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១០/៤៦៤ ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣៥ នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៧៨អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតអគ្គនាយកដ្ឋានជនជាតមនុស្ស ចំណុះក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ



ៗ

## សម្រេច

**មាត្រា១ .-**

ត្រូវបានដាក់ឱ្យចូលនិវត្តន៍មុនពេលកំណត់វរសេនីយ៍ឯក **ចាន់ សុផា** អត្តលេខ ០២០៥៦ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃអង្គារ ៣កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥២៨ អនក្រ.តត

**អនុក្រឹត្យ**

**ស្តីពី**

**ការដំឡើងឋានន្តរសក្តិមន្ត្រីនគរបាលជាតិកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨ /០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហាឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១ .-**

ត្រូវបានដំឡើងឋានន្តរសក្តិថ្នាក់ **វរសេនីយ៍ឯក** ដល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ២រូបៈ

១- វរសេនីយ៍ទោ **លាង ឈីវអាន** អត្តលេខ ៦៨៣១២

២- វរសេនីយ៍ទោ **ម៉ែន ច័ន្ទវាសនា** អត្តលេខ ៨៨៨៨៥។

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ២ កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥២៩ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **សហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនគណៈកម្មាធិការកីឡាជាតិឥណ្ឌូនេស៊ី ចំនួន ១០រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជាមួយកងយោធពលខេមរភូមិន្ទ និងបានផ្តល់អំណោយសម្ភារៈជាឯកសណ្ឋានកងទ័ព ជូនដល់បញ្ជាការដ្ឋានអង្គរក្ស កន្លងមក ដូចមានរាយនាមខាងក្រោម៖

១-លោកជំទាវ TRIWATTY PANCANINGSIH
២-លោក TUBAGUS LUKMAN
៣-លោក ANDIKA MONOARFA

៤-លោក TOMMY PAULUS HERMAWAN
៥-លោក HENDRA BAHARY
៦-លោក MOHAMMAD FAHRIL SETIAWAN
៧-លោក AGENG WARDOYO
៨-លោក MATH ALRAMDAN
៩-លោក DIMAS SAPUTRA PRATAMA
១០-លោក NIZAR JULFIKAR MUNAWAR ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៩កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៣១ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ២៤៣ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៤ ស្តីពីការដំឡើងថ្នាក់ស្មើនាយកដ្ឋានដល់អង្គភាពថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ



៥

## សម្រេច

**មាត្រា១ .–**

ត្រូវបានតែងតាំងលោក **ទឹក ទ៉ាន់ថា** អត្តលេខ **១៦៩០២០០៣៧៥** ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែពិសេស ថ្នាក់លេខ **៥** នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ជាប្រធានមន្ទីររ៉ែនិងថាមពលខេត្តបន្ទាយមានជ័យ នៃក្រសួងរ៉ែនិងថាមពល ជំនួសលោក **សុត វឌ្ឍនា** ដែលបានចូលនិវត្តន៍។

**មាត្រា២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១០កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០២៦

**ឯកឧត្តមរដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៣២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការនិយ័តកម្មដំឡើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា១ ._**

ត្រូវបាននិយ័តកម្មដំឡើងឋានន្តរស័ក្តិ និងថ្នាក់ ក្នុងឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្នុងឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម តាមអតីតភាពការងារ នៅក្រសួងអប់រំ យុវជន និងកីឡា ដល់មន្ត្រីរាជការ **០២ រូប** ដូចមានរាយនាមខាងក្រោម៖

១-ឯកឧត្តម **សាន ចន្ទរ៉ា** ពីវរមន្ត្រី ថ្នាក់លេខ ៣ មកជាថ្នាក់លេខ ១

២-លោកស្រី **ស៊ិន ណារី** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៣ មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣។

**មាត្រា២ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១០កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៣៣ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការបញ្ចប់មុខតំណែងទីប្រឹក្សាក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១១១១ អនក្រ.តត ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការតែងតាំងទីប្រឹក្សា និងជំនួយការក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .-**

ត្រូវបានបញ្ចប់មុខតំណែងពីទីប្រឹក្សាក្រសួងមហាផ្ទៃ ចំនួន ០២រូបៈ

១-លោក **ពៅ ខួន** មានឋានៈស្មើ អគ្គនាយករង

២-លោក **ហ្វាន់ គិញ** មានឋានៈស្មើ ប្រធាននាយកដ្ឋាន។

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ *ពុធ ១០កើត* ខែ *បឋមាសាឍ* ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី*២៨* ខែ *មិថុនា* ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៩៣៤ អនក្រ.តត

# អនុក្រឹត្យ
## ស្ដីពីការផ្ដល់មេដាយការងារ
### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **ការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃរដ្ឋបាលខេត្តត្បូងឃ្មុំ ចំនួន ៤៩រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **មាសការងារ**

| | | |
|---|---|---|
| ១- លោក | ឈីន សុខជា | អភិបាលរង នៃគណៈអភិបាលស្រុកអូររាំងឪ |
| ២- លោក | វ៉ែន ឈុនហួត | អភិបាលរង នៃគណៈអភិបាលស្រុកក្រូចឆ្មារ |
| ៣- លោក | ហ៊ឹម ហួន | ប្រធានការិយាល័យ នៃរដ្ឋបាលស្រុកតំបែរ |
| ៤- លោកស្រី | ភាព សុនីតា | ស្មៀនឃុំប៊ឹស២ ស្រុកក្រូចឆ្មារ |
| ៥- លោក | ឆេង ម៉ានីត | ស្មៀនឃុំកំពង់ទ្រាស ស្រុកក្រូចឆ្មារ។ |

ខ-មេដាយ **ប្រាក់ការងារ**

| | | | |
|---|---|---|---|
| ១- | លោក | ឈីន ចាន់ទី | នាយករងទីចាត់ការ នៃរដ្ឋបាលខេត្តត្បូងឃ្មុំ |
| ២- | លោកស្រី | ម៉ៅ ចាន់ថេន | ស្មៀនឃុំមៀន ស្រុកអូររាំងឪ |
| ៣- | លោក | សៅ សារិ | មន្ត្រី នៃរដ្ឋបាលស្រុកអូររាំងឪ |
| ៤- | លោក | ជុំ ធារ័ត្ន | មន្ត្រី នៃរដ្ឋបាលស្រុកមេមត់ |
| ៥- | លោក | ភិន សៅឌី | ស្មៀនឃុំប៉ឺស១ ស្រុកក្រូចឆ្មារ |
| ៦- | លោក | ហ៊ិត សីហា | ស្មៀនឃុំក្រូចឆ្មារ ស្រុកក្រូចឆ្មារ។ |

គ-មេដាយ **សំរឹទ្ធការងារ**

| | | | |
|---|---|---|---|
| ១- | លោក | ចាន់ សុខាវង្ស | អភិបាលរង នៃគណៈអភិបាលស្រុកអូររាំងឪ |
| ២- | លោក | ធឹង ប៊ុនធា | នាយករងរដ្ឋបាលស្រុកតំបែរ |
| ៣- | លោកស្រី | ញ៉ឹម វាសនា | អនុប្រធានការិយាល័យ នៃរដ្ឋបាលស្រុកតំបែរ |
| ៤- | លោក | ចាន់ សុខចា | ប្រធានការិយាល័យ នៃរដ្ឋបាលស្រុកតំបែរ |
| ៥- | លោក | អ៊ុំ សាក់ | ប្រធានការិយាល័យ នៃរដ្ឋបាលស្រុកតំបែរ |
| ៦- | លោក | ស កុសល | ប្រធានការិយាល័យ នៃរដ្ឋបាលខេត្តត្បូងឃ្មុំ |
| ៧- | លោក | ចាន់ រដ្ឋា | នាយករងរដ្ឋបាល នៃរដ្ឋបាលស្រុកអូររាំងឪ |
| ៨- | លោកស្រី | នុត សុរ៉េន | ប្រធានការិយាល័យ នៃរដ្ឋបាលស្រុកអូររាំងឪ |
| ៩- | លោក | ស្រ៊ី ចាន់សល់ | អនុប្រធានការិយាល័យ នៃរដ្ឋបាលស្រុកតំបែរ |
| ១០- | លោក | ហ៊ូ លាងស្រេង | អនុប្រធានការិយាល័យ នៃរដ្ឋបាលស្រុកតំបែរ |
| ១១- | លោកស្រី | ឡាង សុធី | អនុប្រធានការិយាល័យ នៃរដ្ឋបាលស្រុកអូររាំងឪ |
| ១២- | លោក | ហោ ប៊ុនធឿន | អនុប្រធានការិយាល័យ នៃរដ្ឋបាលស្រុកអូររាំងឪ |
| ១៣- | លោក | អ៊ឹម សុវណ្ណារ៉ា | អនុប្រធានការិយាល័យ នៃរដ្ឋបាលស្រុកអូររាំងឪ |
| ១៤- | លោក | សុខ វ៉ាត | អនុប្រធានការិយាល័យ នៃរដ្ឋបាលស្រុកអូររាំងឪ |
| ១៥- | លោកស្រី | សមុហៈវុទ្ធី | អនុប្រធានការិយាល័យ នៃរដ្ឋបាលស្រុកអូររាំងឪ |
| ១៦- | លោក | ម៉េង គឹមទី | មន្ត្រី នៃរដ្ឋបាលខេត្តត្បូងឃ្មុំ |
| ១៧- | លោក | គិន សំណាង | មន្ត្រី នៃរដ្ឋបាលខេត្តត្បូងឃ្មុំ |
| ១៨- | លោក | កើត សុគន្ធជារ៉ា | មន្ត្រី នៃរដ្ឋបាលខេត្តត្បូងឃ្មុំ |
| ១៩- | លោក | ផាន ចាន់ធៀម | មន្ត្រី នៃរដ្ឋបាលស្រុកតំបែរ |
| ២០- | លោក | គង់ វុទ្ធី | មន្ត្រី នៃរដ្ឋបាលស្រុកតំបែរ |
| ២១- | លោក | ឃួន ពិសិដ្ឋ | មន្ត្រី នៃរដ្ឋបាលស្រុកតំបែរ |
| ២២- | លោក | ស៊ាន សុធារ៉ា | មន្ត្រី នៃរដ្ឋបាលស្រុកតំបែរ |
| ២៣- | លោក | សយ ហេង | មន្ត្រី នៃរដ្ឋបាលស្រុកតំបែរ |
| ២៤- | លោក | ងិន វិនស៊ី | មន្ត្រី នៃរដ្ឋបាលស្រុកអូររាំងឪ |
| ២៥- | លោក | ឱុយ ចាន់ដេត | មន្ត្រី នៃរដ្ឋបាលស្រុកអូររាំងឪ |
| ២៦- | លោក | ម៉ា វុឌ្ឍី | មន្ត្រី នៃរដ្ឋបាលស្រុកអូររាំងឪ |
| ២៧- | លោកស្រី | ប៉ា លីន | មន្ត្រី នៃរដ្ឋបាលស្រុកអូររាំងឪ |

| | | | |
|---|---|---|---|
| ២៨- | លោក | ញ៉ ចំរើន | មន្ត្រី នៃរដ្ឋបាលស្រុកអូររាំង |
| ២៩- | លោក | អោ សុជា | មន្ត្រី នៃរដ្ឋបាលស្រុកអូររាំងឪ |
| ៣០- | លោក | ច្រយ វិចិត្ត | មន្ត្រី នៃរដ្ឋបាលស្រុកអូររាំងឪ |
| ៣១- | លោក | លឹម វ៉ាន់នី | ស្មៀនឃុំដំរិល ស្រុកអូររាំងឪ |
| ៣២- | លោក | សឹក សំ | មន្ត្រី នៃរដ្ឋបាលស្រុកមេមត់ |
| ៣៣- | លោក | ឡេង សុជា | មន្ត្រី នៃរដ្ឋបាលស្រុកមេមត់ |
| ៣៤- | លោក | គួ ឆេង | មន្ត្រី នៃរដ្ឋបាលស្រុកមេមត់ |
| ៣៥- | លោក | សូ នីរតី | មន្ត្រី នៃរដ្ឋបាលស្រុកមេមត់ |
| ៣៦- | លោកស្រី | អាត ចានថា | ស្មៀនឃុំកោះពីរ ស្រុកក្រូចឆ្មារ |
| ៣៧- | លោក | សេង សុបិន្ត | ស្មៀនឃុំឈូក ស្រុកក្រូចឆ្មារ |
| ៣៨- | លោក | ថ្វៃយ ជា | ស្មៀនឃុំទួលស្នួល ស្រុកក្រូចឆ្មារ។ |

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១០កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៣៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការដូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ .-**

ត្រូវបានបំពាក់មេដាយ **ការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃរដ្ឋបាលខេត្តមណ្ឌលគិរី ចំនួន ៦២រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **មាសការងារ**

| | | |
|---|---|---|
| ១- | លោក សាន គឹមអ៊ាប | អភិបាល នៃគណៈអភិបាលស្រុកកែវសីមា |
| ២- | លោក មាស ចន្ទី | អភិបាលរង នៃគណៈអភិបាលក្រុងសែនមនោរម្យ |
| ៣- | លោក ទឹម សេងហួត | អភិបាលរង នៃគណៈអភិបាលស្រុកកែវសីមា |
| ៤- | លោក អ៊ាង សារុត | នាយករដ្ឋបាលស្រុកកោះញែក |
| ៥- | លោក វី រតនា | នាយករងទីចាត់ការ នៃរដ្ឋបាលខេត្តមណ្ឌលគិរី |

៦- លោក ជ័យ វិជ្ជា នាយករងទីចាត់ការ នៃរដ្ឋបាលខេត្តមណ្ឌលគិរី
៧- លោក ងិន សារ៉ា អនុប្រធានអង្គភាពលទ្ធកម្ម រដ្ឋបាលខេត្តមណ្ឌលគិរី
៨- លោក ជឹម រតនៈ នាយករងទីចាត់ការ នៃរដ្ឋបាលខេត្តមណ្ឌលគិរី
៩- លោកស្រី កែវ ដាឡែន នាយករងទីចាត់ការ នៃរដ្ឋបាលខេត្តមណ្ឌលគិរី
១០- លោក គួយ ឧសភា នាយករងទីចាត់ការ នៃរដ្ឋបាលខេត្តមណ្ឌលគិរី
១១- លោកស្រី សារ៉ែន ស្រីលាភ នាយករងរដ្ឋបាលស្រុកពេជ្រាដា
១២- លោក គួយ ពុំ នាយករងរដ្ឋបាលស្រុកកោះញែក
១៣- លោកស្រី ស្រី ដានិត ប្រធានការិយាល័យ នៃរដ្ឋបាលខេត្តមណ្ឌលគិរី
១៤- លោកស្រី ជុំ សេរីដា ប្រធានការិយាល័យ នៃរដ្ឋបាលខេត្តមណ្ឌលគិរី
១៥- លោក ខៀវ សុខលីម ប្រធានការិយាល័យ នៃរដ្ឋបាលខេត្តមណ្ឌលគិរី
១៦- លោក ហែម សិទ្ធា ប្រធានការិយាល័យ នៃរដ្ឋបាលស្រុកកែវសីមា
១៧- លោកស្រី ហែម សុនីកា ប្រធានការិយាល័យ នៃរដ្ឋបាលក្រុងសែនមនោរម្យ
១៨- លោកស្រី ម៉ី សារឹម អនុប្រធានការិយាល័យ នៃរដ្ឋបាលខេត្តមណ្ឌលគិរី
១៩- លោកស្រី ហូ សុខនឿន អនុប្រធានការិយាល័យ នៃរដ្ឋបាលក្រុងសែនមនោរម្យ
២០- លោក ញ៉ាង អ៊ីម អនុប្រធានការិយាល័យ នៃរដ្ឋបាលស្រុកពេជ្រាដា។

ខ-មេដាយ **ប្រាក់ការងារ**

១- លោក ពេជ ពិចិត្រ អភិបាលរង នៃគណៈអភិបាលស្រុកកោះញែក
២- លោក សុះ មីឡែន អភិបាលរង នៃគណៈអភិបាលស្រុកកែវសីមា
៣- លោកស្រី ស៊ន់ សុខគង់ អភិបាលរង នៃគណៈអភិបាលស្រុកអូររាំង
៤- លោក រិន សុភា នាយកទីចាត់ការ នៃរដ្ឋបាលខេត្តមណ្ឌលគិរី
៥- លោក តាំង បញ្ញា អនុប្រធានអង្គភាពច្រកចេញចូលតែមួយ រដ្ឋបាលខេត្តមណ្ឌលគិរី
៦- លោក ផូរ សំអន នាយករងទីចាត់ការ នៃរដ្ឋបាលខេត្តមណ្ឌលគិរី
៧- លោក ហម សុផង់ នាយករងរដ្ឋបាលស្រុកកែវសីមា
៨- លោក កែវ ឬទ្ធី ប្រធានការិយាល័យ នៃរដ្ឋបាលខេត្តមណ្ឌលគិរី
៩- លោក គឹម សុគន្ធា ប្រធានការិយាល័យ នៃរដ្ឋបាលខេត្តមណ្ឌលគិរី
១០- លោក ម្រើក ផុត ប្រធានការិយាល័យ នៃរដ្ឋបាលខេត្តមណ្ឌលគិរី
១១- លោក ហុង ទិត្យ ប្រធានការិយាល័យ នៃរដ្ឋបាលខេត្តមណ្ឌលគិរី
១២- លោក ទាវ ទិត្យចាន់ដារ៉ា ប្រធានការិយាល័យ នៃរដ្ឋបាលខេត្តមណ្ឌលគិរី
១៣- លោកស្រី សុខ សុគន្ធារ៉ា ប្រធានការិយាល័យ នៃរដ្ឋបាលខេត្តមណ្ឌលគិរី
១៤- លោក ខាន់ ស្ម័គ្រ ប្រធានអង្គភាពលទ្ធកម្ម រដ្ឋបាលក្រុងសែនមនោរម្យ
១៥- លោកស្រី សែត ធឿន ប្រធានការិយាល័យ នៃរដ្ឋបាលក្រុងសែនមនោរម្យ
១៦- លោក សឿន សារី ប្រធានការិយាល័យ នៃរដ្ឋបាលស្រុកពេជ្រាដា
១៧- លោកស្រី ឡាយ សារ៉ុម អនុប្រធានការិយាល័យ នៃរដ្ឋបាលខេត្តមណ្ឌលគិរី
១៨- លោកស្រី ថន គឹមស៊ាង អនុប្រធានការិយាល័យ នៃរដ្ឋបាលខេត្តមណ្ឌលគិរី
១៩- លោកស្រី សុខ ហាន អនុប្រធានការិយាល័យ នៃរដ្ឋបាលខេត្តមណ្ឌលគិរី
២០- លោកស្រី សួង ជារ៉ា អនុប្រធានការិយាល័យ នៃរដ្ឋបាលខេត្តមណ្ឌលគិរី
២១- លោក កែវ បញ្ញា អនុប្រធានការិយាល័យ នៃរដ្ឋបាលខេត្តមណ្ឌលគិរី

| | |
|---|---|
| ២២- លោក ឃុន សុទ្ធារ៉េ | អនុប្រធានការិយាល័យ នៃរដ្ឋបាលខេត្តមណ្ឌលគិរី |
| ២៣- លោកស្រី ឈុត សំអាន | អនុប្រធានការិយាល័យ នៃរដ្ឋបាលខេត្តមណ្ឌលគិរី |
| ២៤- លោកស្រី ឡុក សុភាព | អនុប្រធានការិយាល័យច្រកចេញចូលតែមួយ រដ្ឋបាលក្រុងសែនមនោរម្យ |
| ២៥- លោក ជឹម ផល្លី | អនុប្រធានការិយាល័យ នៃរដ្ឋបាលស្រុកកែវសីមា |
| ២៦- លោក ស្រប កឹ | អនុប្រធានការិយាល័យ នៃរដ្ឋបាលស្រុកពេជ្រាដា |
| ២៧- លោក ឈ ឡៃផេង | អនុប្រធានការិយាល័យ នៃរដ្ឋបាលស្រុកពេជ្រាដា |
| ២៨- លោក មាស សុខខេង | អនុប្រធានការិយាល័យ នៃរដ្ឋបាលស្រុកពេជ្រាដា |
| ២៩- លោកស្រី ទិន ស្រីម៉ៅ | មន្ត្រី នៃរដ្ឋបាលខេត្តមណ្ឌលគិរី |
| ៣០- លោក ផែម សុភ័ក្រ្ត | ស្មៀនឃុំស្រែព្រះ ស្រុកកែវសីមា។ |

គ-មេដាយ **សំរឹទ្ធភារវាវ**

| | |
|---|---|
| ១- លោក ព្រៀម សុនរ៉ាវី | អនុប្រធានអង្គភាពលទ្ធកម្ម រដ្ឋបាលខេត្តមណ្ឌលគិរី |
| ២- លោកស្រី អ៊ុក សេរីរ័ត្ន | នាយករដ្ឋបាលស្រុកអូររាំង |
| ៣- លោក ភី ភាន់ | នាយករងរដ្ឋបាលស្រុកកែវសីមា |
| ៤- លោក សាលី ប៉ោ | ប្រធានការិយាល័យ នៃរដ្ឋបាលស្រុកអូររាំង |
| ៥- លោក ចាន់ សាមុត | ប្រធានអង្គភាពលទ្ធកម្ម រដ្ឋបាលស្រុកអូររាំង |
| ៦- លោក លីន បូវណ្ណៈ | ប្រធានការិយាល័យ នៃរដ្ឋបាលស្រុកពេជ្រាដា |
| ៧- លោកស្រី ស៊ូវ៉ាង សម័យហ្វូនិច | អនុប្រធានការិយាល័យ នៃរដ្ឋបាលស្រុកកែវសីមា |
| ៨- លោកស្រី ស៊ឹម ថុនា | អនុប្រធានការិយាល័យ នៃរដ្ឋបាលក្រុងសែនមនោរម្យ |
| ៩- លោកស្រី ហួត នី | មន្ត្រី នៃរដ្ឋបាលស្រុកពេជ្រាដា |
| ១០- លោកស្រី ង៉ែត សុភាព | មន្ត្រី នៃរដ្ឋបាលស្រុកកែវសីមា |
| ១១- លោក ឱក ថេង | ស្មៀនឃុំស្រែខ្ទុម ស្រុកកែវសីមា |
| ១២- លោក ម៉ាន លុច | ស្មៀនសង្កាត់រមនា ក្រុងសែនមនោរម្យ។ |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១០កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២៣/០០៧ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ ដែលប្រកាស ឱ្យប្រើក្រមបរិស្ថាននិងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ២៤១ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ២៣៨ អនក្រ.បក ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការបង្កើតមូលនិធិ បរិស្ថាននិងសង្គម
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា៦ មាត្រា៨ មាត្រា១០ និងមាត្រា១១ នៃអនុក្រឹត្យលេខ២៣៨ អនក្រ.បក ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការបង្កើតមូលនិធិបរិស្ថាននិងសង្គម

- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ១៥៧ សសរ ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពគណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**សម្រេច**

**ប្រការ១ .-**

ត្រូវបានតែងតាំងឯកឧត្តម **រស់ សីរុណា** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអនុប្រធានគណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គម ជំនួសឯកឧត្តម **យ៉េត ទីណែល**។

**ប្រការ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ០៩ សរ

## សារាចរ
## ស្តីពី
## ការរៀបចំទិវាជាតិសហគ្រាសធុនមីក្រូ តូច និងមធ្យម លើកទី៣ ឆ្នាំ២០២៦

រាជរដ្ឋាភិបាលកម្ពុជា បានកំណត់ថ្ងៃទី២៧ ខែមិថុនា ជារៀងរាល់ឆ្នាំជាទិវាជាតិសហគ្រាសធុនមីក្រូ តូច និងមធ្យម តាមរយៈអនុក្រឹត្យលេខ១៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤ ស្តីពីទិវាជាតិសហគ្រាសធុនមីក្រូ តូច និងមធ្យម ដោយស្របតាមសេចក្តីសម្រេចលេខ A/RES/71/279 នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៧ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងគោលបំណងដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍដោយចីរភាពឆ្នាំ២០៣០ និងបន្តជំរុញការអភិវឌ្ឍវិស័យសហគ្រាសធុនមីក្រូ តូច និងមធ្យម ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ និងជាកម្លាំងចលករសំខាន់ក្នុងការបង្កើតការងារ លើកកម្ពស់ជីវភាពប្រជាពលរដ្ឋ ពង្រឹងភាពធន់នៃសេដ្ឋកិច្ចនិងជំរុញការប្រកួតប្រជែងរបស់កម្ពុជា ក្នុងបរិបទសេដ្ឋកិច្ចពិភពលោក ដែលកំពុងមានភាពមិនច្បាស់លាស់និងការប្រែប្រួលយ៉ាងឆាប់រហ័ស។ សម្រាប់ឆ្នាំ២០២៦នេះ រាជរដ្ឋាភិបាលសម្រេចរៀបចំទិវាជាតិសហគ្រាសធុនមីក្រូ តូច និងមធ្យម លើកទី៣ ក្រោមប្រធានបទ **«សាងស្ពានសម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យមឆ្ពោះទៅកាន់ទីផ្សារ»** ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៦ ដោយផ្តោតលើគោលបំណងសំខាន់ៗដូចខាងក្រោម៖

១- ផ្សព្វផ្សាយគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីរបស់រាជរដ្ឋាភិបាលក្នុងការគាំទ្រសហគ្រាសធុនមីក្រូ តូច និងមធ្យម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីលើកកម្ពស់ផលិតភាព គុណភាព ការប្រកួតប្រជែង ជាមួយការត្រៀមខ្លួនរបស់សហគ្រាសធុនមីក្រូ តូច និងមធ្យម សម្រាប់ការចាកចេញរបស់កម្ពុជាពីឋានៈប្រទេសអភិវឌ្ឍតិចតួចនៅចុងឆ្នាំ២០២៩ នាពេលខាងមុខ។

២- បង្កើតវេទិកាតភ្ជាប់រវាងសហគ្រាសធុនមីក្រូ តូច និងមធ្យម ជាមួយទីផ្សារអ្នកផ្គត់ផ្គង់ វិនិយោគិន គ្រឹះស្ថានហិរញ្ញវត្ថុ វេទិកាពាណិជ្ជកម្មឌីជីថល និងសហគ្រាសធំៗ ដើម្បីពង្រឹងខ្សែច្រវាក់តម្លៃនិងជំរុញការផ្គត់ផ្គង់ក្នុងស្រុក។

៣- លើកកម្ពស់ស្មារតីស្នេហាជាតិនិងការគាំទ្រផលិតផលក្នុងស្រុក តាមរយៈការជំរុញឱ្យប្រជាពលរដ្ឋកម្ពុជាងាកមកប្រើប្រាស់ផលិតផលក្នុងស្រុក «ផលិតនៅកម្ពុជា» ដែលមានគុណភាព សុវត្ថិភាព ស្តង់ដា និងការវេចខ្ចប់ប្រកបដោយគុណភាព សោភណភាព និងការទាក់ទាញ។

៤- លើកទឹកចិត្តសហគ្រាសធុនមីក្រូ តូច និងមធ្យម ឱ្យប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនិងនវានុវត្តន៍ក្នុងការធ្វើទំនើបកម្មផលិតកម្ម ការគ្រប់គ្រងអាជីវកម្ម និងការធ្វើទីផ្សារ។

៥- ពង្រឹងភាពធន់នៃសហគ្រាសធុនមីក្រូ តូច និងមធ្យម ក្នុងបរិបទភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចពិភពលោក ការប្រកួតប្រជែងតំបន់ និងបញ្ហាប្រឈមផ្នែកភូមិសាស្ត្រនយោបាយនិងពាណិជ្ជកម្មអន្តរជាតិ។



៥

ដើម្បីឱ្យការរៀបចំទិវាជាតិនេះ ប្រព្រឹត្តទៅដោយរលូនប្រកបដោយភាពអធិកអធម រាជរដ្ឋាភិបាល សូមដាក់ចេញនូវវិធានការណែនាំដូចខាងក្រោម៖

១- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ត្រូវទទួលបន្ទុករៀបចំទិវាជាតិនេះនិងត្រូវផលិតជាវីដេអូនិងខ្លឹមសារឯកសារផ្សេងៗដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលរាជធានី ខេត្ត អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ និងវិស័យឯកជន ដើម្បីធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ នៅទូទាំងប្រទេស។

២- ក្រសួងព័ត៌មានត្រូវណែនាំដល់ប្រព័ន្ធឃោសនារបស់រដ្ឋ ឯកជន និងបណ្ដាញសារព័ត៌មានដូចជា វិទ្យុ ទូរទស្សន៍ កាសែត បណ្ដាញសង្គម និងមធ្យោបាយផ្សព្វផ្សាយផ្សេងទៀតឱ្យធ្វើការផ្សព្វផ្សាយសារាចរ សារលិខិត **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងវីដេអូ ខ្លឹមសារឯកសារផ្សេងៗនៃទិវាជាតិនេះឱ្យបានផុសផុល។

៣- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធនានាត្រូវចូលរួមសហការគាំទ្រ ដើម្បីឱ្យទិវាជាតិសហគ្រាសធុនមីក្រូ តូច និងមធ្យម លើកទី៣ ឆ្នាំ២០២៦ ប្រព្រឹត្តទៅបានដោយរលូន តាមការស្នើសុំសហការរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ទៅតាមលទ្ធភាពរបស់ក្រសួង ស្ថាប័ន។

៤- គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធនានាត្រូវរៀបចំចងបដាពាក្យស្លោក នៅតាមអង្គភាពនិងទីសាធារណៈ តាមខ្លឹមសារដូចខាងក្រោម៖

- អបអរសាទរទិវាជាតិសហគ្រាសធុនមីក្រូ តូច និងមធ្យម លើកទី៣ ឆ្នាំ២០២៦!
- ប្រើប្រាស់ផលិតផលខ្មែរ គឺស្នេហាជាតិ
- ប្រើប្រាស់ផលិតផលខ្មែរ បង្កើតការងារ និងបង្កើនចំណូលសម្រាប់ប្រជាជនខ្មែរ
- មោទនភាពផលិតផលខ្មែរ មោទនភាពជាតិខ្មែរ
- សហគ្រាសធុនមីក្រូ តូច និងមធ្យមមានភាពជន់ សេដ្ឋកិច្ចខ្មែររឹងមាំ ប្រទេសជាតិរុងរឿង
- ផ្គត់ផ្គង់ដោយខ្មែរ ផលិតដោយខ្មែរ វេចខ្ចប់ដោយខ្មែរ រីកចម្រើនសម្រាប់ខ្មែរទាំងអស់គ្នា
- ប្រើប្រាស់ផលិតផលក្នុងស្រុក គាំទ្រសហគ្រាសធុនមីក្រូ តូច និងមធ្យម កម្ពុជា
- សាងស្ពានពីផលិតផលខ្មែរទៅកាន់ទីផ្សារជាតិនិងអន្តរជាតិ
- ហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិជាគន្លឹះនៃភាពរីកចម្រើនរបស់សហគ្រាសធុនមីក្រូ តូច និង មធ្យម កម្ពុជា។

ទទួលបានសារាចរនេះ ទីស្ដីការគណៈរដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ត្រូវផ្សព្វផ្សាយ និងអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ពុធ ១០កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១០ សរ

# សារាចរ
# ស្តីពី
# ការផ្អាកការប្រារព្ធព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ឆ្នាំ២០២៦ នៅរាជធានីភ្នំពេញ

អនុលោមតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ០៩ សរណន ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ សម្រាប់អនុវត្តជាអចិន្ត្រៃយ៍ ស្តីពីការរៀបចំចាត់តាំងព្រះរាជពិធីបុណ្យទ្វាទសមាស បុណ្យប្រពៃណីជាតិ ប្រពៃណីសាសនា បុណ្យជាតិ-បុណ្យអន្តរជាតិ រាជរដ្ឋាភិបាលតែងតែប្រារព្ធព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ជារៀងរាល់ឆ្នាំ ចំនួន៣(បី)ថ្ងៃ នៅថ្ងៃ១៤កើត ១៥កើត និង១រោច ខែកត្តិក ដើម្បីអបអរសាទរព្រះរាជពិធីបុណ្យប្រពៃណីជាតិ និងបន្តរក្សាទំនៀមទម្លាប់ដ៏ប្រពៃរបស់ខ្មែរដែលមានតាំងពីយូរលង់មកហើយ ដោយមានរៀបចំពិធីប្រណាំងទូកង បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក នៅតាមដងទន្លេសាប មុខព្រះបរមរាជវាំង រាជធានីភ្នំពេញ និងដោយឡែកនៅតាមបណ្តាខេត្តមួយចំនួនក៏បានរៀបចំពិធីនេះផងដែរ។

បច្ចុប្បន្ន ដោយសាររាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់ខ្ពស់លើស្ថានការណ៍ចំពោះមុខនៅតាមព្រំដែនកម្ពុជា-ថៃ ជាពិសេសការដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋភៀសសឹក ក៏ដូចជាកិច្ចការអាទិភាពចំពោះមុខមួយចំនួន រាជរដ្ឋាភិបាលសូមដាក់ចេញនូវវិធានការណែនាំដូចខាងក្រោម៖

១- ផ្អាកការប្រារព្ធព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក នៅតាមដងទន្លេសាប មុខព្រះបរមរាជវាំង រាជធានីភ្នំពេញ ដែលគ្រោងនឹងប្រព្រឹត្តទៅនៅថ្ងៃ១៤កើត ១៥កើត និង១រោច ខែកត្តិក ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ២៥៧០ ត្រូវនឹងថ្ងៃទី២៣ ទី២៤ និងទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៦។

២- ការរៀបចំពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក នៅតាមបណ្តាខេត្តនានា អាចប្រព្រឹត្តទៅជាធម្មតាតាមទំនៀមទម្លាប់ប្រពៃណី និងតាមលទ្ធភាពជាក់ស្តែងរបស់អាជ្ញាធរ និងប្រជាពលរដ្ឋ។

៣- ការឈប់សម្រាករបស់មន្ត្រីរាជការ និយោជិត កម្មករ ចំនួន៣(បី)ថ្ងៃ ក្នុងឱកាសព្រះរាជពិធីនេះ នៅរក្សាដដែល ដូចខ្លឹមសារដែលមានចែងក្នុងអនុក្រឹត្យលេខ១៦៧ អនក្រ.បក ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៥ ស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០២៦។

៤- ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត និងរដ្ឋបាលរាជធានី ខេត្ត ត្រូវបន្តយកចិត្តទុកដាក់ខ្ពស់ចំពោះសុខទុក្ខ និងសហការដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋភៀសសឹក យុទ្ធជននិងគ្រួសារយុទ្ធជន ដែលរងរបួស ពលី និងកំពុងឈរជើងការពារទឹកដី ព្រមទាំងអតីតយុទ្ធជន នៅតាមមូលដ្ឋានរៀងៗខ្លួន។

៥- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបន្តយកចិត្តទុកដាក់ សម្របសម្រួល និងបង្កលក្ខណៈងាយស្រួលដល់ការស្វែងរកការងាររបស់ពលករខ្មែរដែលបានវិលត្រឡប់មកពីប្រទេសថៃវិញ និងបន្តសហការជាមួយក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត និងរដ្ឋបាលរាជធានី ខេត្ត ដើម្បីផ្សព្វផ្សាយឱកាសការងារដល់ប្រជាពលរដ្ឋ ជាពិសេសពលករខ្មែរនៅតាមមូលដ្ឋាននីមួយៗ។

៦- ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលរាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់ចំពោះជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងត្រូវបន្តខិតខំពង្រឹងនិងជំរុញសេដ្ឋកិច្ចមូលដ្ឋាន ជានាស្ថិរភាពថ្លៃ ខ្សែច្រវាក់ផលិតកម្មនិងការផ្គត់ផ្គង់ គាំទ្រការផលិតក្នុងស្រុកនិងជានាការប្រកួតប្រជែង ព្រមទាំងដោះស្រាយនូវបញ្ហាជារចនាសម្ព័ន្ធរាំរែនានាដែលរាំងស្ទះដល់សកម្មភាពផលិតកម្ម អាជីវកម្ម ធុរកិច្ច និងវិនិយោគ។

៧- ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលរាជធានី ខេត្ត ត្រូវបន្តយកចិត្តទុកដាក់ខ្ពស់លើការងារត្រៀមបង្ការគ្រោះធម្មជាតិនានា ពិសេសគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតដោយសារកូនរដូវប្រាំង និងត្រូវយកចិត្តទុកដាក់ចាត់វិធានការរក្សាទឹកឱ្យបានច្រើននៅពាក់កណ្តាលនិងចុងរដូវវស្សានេះ ដើម្បីត្រៀមបង្ការការខ្វះខាតទឹក និងការកើនឡើងកម្តៅនៅរដូវប្រាំងដោយសារបាតុភូតអែលនីញ៉ូ (El Niño) បណ្តាលឱ្យរដូវប្រាំងឆ្នាំ២០២៧ ខាងមុខអាចនឹងអូសបន្លាយរយៈពេលយូរ។

៨- ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត និងសមត្ថកិច្ចពាក់ព័ន្ធ ត្រូវថែរក្សា ការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម និងបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព។

ទទួលបានសារាចរនេះ ទីស្តីការគណៈរដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត រដ្ឋបាលរាជធានី ខេត្ត និងសមត្ថកិច្ចដែលពាក់ព័ន្ធ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

STATE SECRETARIAT OF BORDER AFFAIRS

**រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន**

លេខ: ០១៣/២៦ រកត. សសរ

ទីស្ដីការគណៈរដ្ឋមន្ត្រី
ចូល លេខ 3824
ថ្ងៃទី 30 ខែ 07 ឆ្នាំ 26
ម៉ោង 9H18

## សេចក្ដីសម្រេច
## ស្ដីពី
## ការទទួលស្គាល់សមាសភាពអនុគណៈកម្មការព្រំដែនខេត្តមណ្ឌលគិរី
## រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២៣/០១៨ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ២១ អនក្រ.បក ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញសេចក្ដីសម្រេចលេខ១៦០ សសរ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៤ ស្ដីពីការបង្កើតគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម
- បានឃើញសេចក្ដីសម្រេចលេខ៧៧ សសរ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥ ស្ដីពីការបង្កើតអនុគណៈកម្មការព្រំដែនខេត្តជាប់ព្រំដែនជាមួយប្រទេសជិតខាង
- យោងតាមតម្រូវការចាំបាច់របស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។

## សម្រេច

**ប្រការ១ .-**

ត្រូវបានទទួលស្គាល់សមាសភាពអនុគណៈកម្មការព្រំដែនខេត្តជាប់ព្រំដែនខេត្តមណ្ឌលគិរី ចំណុះរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ថង សាវុន** | អភិបាលនៃគណៈអភិបាលខេត្ត | ប្រធាន |
| ២- ឧត្តមសេនីយ៍ទោ **ចន ចាយ** | មេបញ្ជាការរងយោធភូមិភាគទី១ | អនុប្រធាន |
| ៣- លោក **ហ៊ាញ ប៊ុណ្ណា** | អភិបាលរងនៃគណៈអភិបាលខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- លោក **នាង វណ្ណៈ** | នាយករដ្ឋបាលសាលាខេត្ត | សមាជិក |
| ៥- ឧត្តមសេនីយ៍ទោ **សាន គឹមអឿន** | មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត | សមាជិក |
| ៦- ឧត្តមសេនីយ៍ទោ **ឡោ សុខា** | ស្នងការនៃស្នងការដ្ឋាននគរបាលខេត្ត | សមាជិក |
| ៧- ឧត្តមសេនីយ៍ត្រី **ហែម ប៉ូណារ៉ែល** | មេបញ្ជាការកងរាជអាវុធហត្ថខេត្ត | សមាជិក |
| ៨- លោក **លឹម ស្រេង** | ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត | សមាជិក |
| ៩- លោកបណ្ឌិត **សុខ ឃាង** | ប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្ត | សមាជិក |
| ១០- លោក **ហាស់ វិបុល** | ប្រធានមន្ទីរបរិស្ថានខេត្ត | សមាជិក |
| ១១- លោក **ខែម តារម្យ** | ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្ត | សមាជិក |
| ១២- លោក **ធន់ សារី** | ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត | សមាជិក |
| ១៣- លោក **រស់ គឹមធន** | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត | សមាជិក |
| ១៤- លោក **ទី សុផល** | ប្រធានមន្ទីររ៉ែ និងថាមពលខេត្ត | សមាជិក |
| ១៥- លោក **សាន គឹមអ៊ាប** | អភិបាលនៃគណៈអភិបាលស្រុកកែវសីមា | សមាជិក |
| ១៦- លោក **សៀក មុន្នី** | អភិបាលនៃគណៈអភិបាលស្រុកអូររាំង | សមាជិក |
| ១៧- លោក **វណ្ណា ម៉ាប់** | អភិបាលនៃគណៈអភិបាលស្រុកពេជ្រាដា | សមាជិក |
| ១៨- លោក **សី ទូច** | អភិបាលនៃគណៈអភិបាលស្រុកកោះញែក | សមាជិក |
| ១៩- ឧត្តមសេនីយ៍ត្រី **ស៊ុន ប៊ុនធឿន** | ស្នងការរងនៃស្នងការដ្ឋាននគរបាលខេត្ត ទទួលបន្ទុកការងារព្រំដែន | សមាជិក |
| ២០- វរសេនីយ៍ទោ **ស្រ៊ុន សុភា** | ស្នងការរងនៃស្នងការដ្ឋាននគរបាលខេត្ត ទទួលបន្ទុកការងារព្រំដែន | សមាជិក |
| ២១- វរសេនីយ៍ឯក **ឌិន ស៊ីន** | មេបញ្ជាការវរសេនាតូចនគរបាល ការពារព្រំដែនគោកលេខ៣០៣ | សមាជិក |
| ២២- វរសេនីយ៍ឯក **អន ប៊ុនធូ** | មេបញ្ជាការវរសេនាតូចនគរបាល ការពារព្រំដែនគោកលេខ៦២១ | សមាជិក |
| ២៣- វរសេនីយ៍ទោ **ផាន ប៊ុនធឿន** | មេបញ្ជាការវរសេនាតូចអន្តរាគមន៍លេខ១១៥ នៃតំបន់ប្រតិបត្តិការសឹករងមណ្ឌលគិរី | សមាជិក |

៦៨

| | | |
|---|---|---|
| ២៤- វរសេនីយ៍ត្រី **តី គុណា** | មេបញ្ជាការវរសេនាតូចអន្តរាគមន៍លេខ១១៦ នៃតំបន់ប្រតិបត្តិការសឹករងមណ្ឌលគិរី | សមាជិក |
| ២៥- លោក **សុក ម៉ារឌី** | ប្រធានការិយាល័យទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២៦- លោក **ខ៊ាន់ សារ៉ាឌុធ** | ប្រធានទីស្នាក់ការច្រកទ្វារព្រំដែនទេ្វភាគីណាំលៀ | សមាជិក |
| ២៧- លោក **ផូរ សំអន** | ប្រធានទីស្នាក់ការច្រកទ្វារព្រំដែនទេ្វភាគីឡាប៉ាខេ | សមាជិក |
| ២៨- លោក **ទាវ ទិត្យចាន់ដារ៉ា** | ប្រធានទីស្នាក់ការច្រកទ្វារព្រំដែនទេ្វភាគីដាក់ដាំ | សមាជិក |
| ២៩- វរសេនីយ៍ទោ **ហ៊ីន គាសេខ** | នាយប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនទេ្វភាគីឡាប៉ាខេ | សមាជិក |
| ៣០- វរសេនីយ៍ទោ **សំរិត ណាយ** | នាយប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនទេ្វភាគីណាំលៀ | សមាជិក |
| ៣១- វរសេនីយ៍ទោ **យូ សុធា** | នាយប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនទេ្វភាគីដាក់ដាំ | សមាជិក។ |

**ប្រការ២ .-**

អនុគណៈកម្មការព្រំដែនខេត្តមណ្ឌលគិរី មានភារកិច្ចដូចបានកំណត់នៅក្នុងសេចក្តីសម្រេចលេខ៧៧ សសរ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥ ស្តីពីការបង្កើតអនុគណៈកម្មការព្រំដែនខេត្តជាប់ព្រំដែនជាមួយប្រទេសជិតខាង។

**ប្រការ៣ .-**

សមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៧ កើត ខែ ចេត្រ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០២៦

**រដ្ឋមន្ត្រី**

**ឡាំ ជា**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

STATE SECRETARIAT OF BORDER AFFAIRS

**រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន**
លេខ: ០១៤/២៦ រកព-សសរ

ទីស្តីការគណៈរដ្ឋមន្ត្រី
ចូល
លេខ 3825
ថ្ងៃទី 30 ខែ 07 ឆ្នាំ 26
ម៉ោង ៩H21

# សេចក្តីសម្រេច
# ស្តីពី
# ការទទួលស្គាល់សមាសភាពអនុគណៈកម្មការព្រំដែនខេត្តក្រចេះ

## រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២៣/០១៨ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ២១ អនក្រ.បក ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញសេចក្តីសម្រេចលេខ១៦០ សសរ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម
- បានឃើញសេចក្តីសម្រេចលេខ៧៧ សសរ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥ ស្តីពីការបង្កើតអនុគណៈកម្មការព្រំដែនខេត្តជាប់ព្រំដែនជាមួយប្រទេសជិតខាង
- យោងតាមតម្រូវការចាំបាច់របស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។

## សម្រេច

**ប្រការ១ .-**

ត្រូវបានទទួលស្គាល់សមាសភាពអនុគណៈកម្មការព្រំដែនខេត្តជាប់ព្រំដែនខេត្តក្រចេះ ចំណុះរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **វ៉ា ថន** | អភិបាលនៃគណៈអភិបាលខេត្ត | ប្រធាន |
| ២- ឧត្តមសេនីយ៍ទោ **ណៃ គឹមឡឹង** | មេបញ្ជាការរងយោធភូមិភាគទី២និងជាមេបញ្ជាការតំបន់ប្រតិបត្តិការសឹករងក្រចេះ | អនុប្រធាន |
| ៣- លោក **គឹម គីរ៉ា** | អភិបាលរងនៃគណៈអភិបាលខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- លោក **ម៉ែន វណ្ណា** | នាយករដ្ឋបាលសាលាខេត្ត | សមាជិក |
| ៥- ឧត្តមសេនីយ៍ទោ **អ៊ូ សុបុណ្ណា** | ស្នងការនគរបាលខេត្ត | សមាជិក |
| ៦- ឧត្តមសេនីយ៍ត្រី **សាក់ សារ៉ាង** | មេបញ្ជាការកងរាជអាវុធហត្ថខេត្ត | សមាជិក |
| ៧- លោក **អ៊ុចសុផាន់ណូ** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ៨- លោក **ជា វេង** | ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត | សមាជិក |
| ៩- លោក **អ៊ូ សុបុណ្ណាភា** | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | សមាជិក |
| ១០- លោក **ទ្រី សុភក្តិ** | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត | សមាជិក |
| ១១- លោក **គា ប៊ូ** | ប្រធានមន្ទីរបរិស្ថានខេត្ត | សមាជិក |
| ១២- លោក **ហេង វត្តម៉ូនីជា** | ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្ត | សមាជិក |
| ១៣- លោក **លឹម ជាវហាវ** | ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត | សមាជិក |
| ១៤- លោក **សាំង ម៉ុនថេន** | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត | សមាជិក |
| ១៥- លោក **វត្ត តុលា** | ប្រធានមន្ទីររ៉ែ និងថាមពលខេត្ត | សមាជិក |
| ១៦- លោក **សេក ម៉ុនហេង** | អភិបាលនៃគណៈអភិបាលក្រុងក្រចេះ | សមាជិក |
| ១៧- លោក **ឃិន វណ្ណៈ** | អភិបាលនៃគណៈអភិបាលស្រុកចិត្របុរី | សមាជិក |
| ១៨- លោកស្រី **គង់ លីមហូ** | អភិបាលនៃគណៈអភិបាលស្រុកឆ្លូង | សមាជិក |
| ១៩- លោក **សូម សារិត** | អភិបាលនៃគណៈអភិបាលស្រុកព្រែកប្រសព្វ | សមាជិក |
| ២០- លោក **គង់ មេត្តា** | អភិបាលនៃអភិបាលស្រុកសំបូរ | សមាជិក |
| ២១- លោក **សាម ណារល់** | អភិបាលនៃអភិបាលស្រុកស្នួល | សមាជិក |
| ២២- លោក **ឈា ផល្លី** | អភិបាលនៃគណៈអភិបាលស្រុកអូរគ្រៀងសែនជ័យ | សមាជិក |
| ២៣- លោក **លាង មេងគីម** | ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងស្រែ | សមាជិក |
| ២៤- លោក **ម៉េត ឡៃហេង** | ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនទេ្វភាគីជ័យឃ្លាំង | សមាជិក |

| | | |
|---|---|---|
| ២៥- ឧត្តមសេនីយ៍ត្រី **ជុំ ម៉ុណ្ណារ័ត្ន** | នាយប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍ ប្រចាំច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងស្រែ | សមាជិក |
| ២៦- វរសេនីយ៍ទោ **អៀម សុខលីម** | នាយប៉ុស្តិ៍នគរបាល ប្រចាំច្រកទ្វារព្រំដែន ទ្វេភាគីជ័យឃ្លាំង | សមាជិក |
| ២៧- វរសេនីយ៍ទោ **មាស សុភាព** | មេបញ្ជាការវរសេនាតូចលេខ២២៥ | សមាជិក |
| ២៨- វរសេនីយ៍ទោ **អ៊ីច សុខរ៉ាន់** | មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៦១៩ | សមាជិក។ |

**ប្រការ២ .-**

អនុគណៈកម្មការព្រំដែនខេត្តក្រចេះ មានភារកិច្ចដូចបានកំណត់នៅក្នុងសេចក្តីសម្រេចលេខ៧៧ សសរ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥ ស្តីពីការបង្កើតអនុគណៈកម្មការព្រំដែនខេត្តជាប់ព្រំដែនជាមួយប្រទេសជិតខាង។

**ប្រការ៣ .-**

សមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៧ កើត ខែ ពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០២៦

**រដ្ឋមន្ត្រី**

**ឡាំ ជា**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៥៦........សហវ.[illegible]

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការបង្កើតរង្វាន់ចំណូល
# នៅរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២៣/០២០ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២៥/០៤០ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៤៥ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ ស្តីពីគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៥៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការបែកចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦
- បានឃើញបញ្ជាលេខ ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញប្រកាសលេខ៥៤៤ សហវ.ប្រក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិការបស់អង្គភាពថវិកា
- បានឃើញប្រកាសលេខ ១១៥៨ សហវ.ប្រក.អរតន ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ប្រកាសស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ៩៧៤ សហវ.ប្រក.អរតន ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរដ្ឋទេយ្យចំណូលសម្រាប់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ១០៦៥ សហវ.ប្រក.អថ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិ សម្រាប់ឆ្នាំ២០២៦
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល

## សម្រេច

**ប្រការ ១._**

ត្រូវបានបង្កើតរដ្ឋទេយ្យចំណូលនៅរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដើម្បីធ្វើការប្រមូលចំណូល

មិនមែនសារពើពន្ធផ្សេងៗ។ បញ្ជីរាយមុខសញ្ញាចំណូលដែលរដ្ឋទេយ្យករត្រូវបានអនុញ្ញាត ឱ្យប្រមូលមានដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. អនុគណនី | ៧៣០០១ | ផលទុនអាកាសចរណ៍ស៊ីវិល | ចំនួនទឹកប្រាក់ | ១៧៤ ២០០ ០០០ ០០០ រៀល |
| ២. អនុគណនី | ៧៣០២៣ | ផលពីការបង្កើតសហគ្រាស | ចំនួនទឹកប្រាក់ | ៧៥០ ០០០ ០០០ រៀល |
| ៣. អនុគណនី | ៧៣០២៤ | ផលពីការបង់សិទ្ធិប្រឡង | ចំនួនទឹកប្រាក់ | ៨៧ ០០០ ០០០ រៀល |
| ៤. អនុគណនី | ៧៣០៤៨ | ផលពីសេវាផ្សេងៗទៀត | ចំនួនទឹកប្រាក់ | ២០ ០០០ ០០០ រៀល |
| ៥. អនុគណនី | ៧៣០៦៦ | ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក | ចំនួនទឹកប្រាក់ | ៦៥ ០០០ ០០០ រៀល |
| ៦. អនុគណនី | ៧៣០៨៧ | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាន | ចំនួនទឹកប្រាក់ | ២០០ ០០០ ០០០ រៀល |

**សរុបទឹកប្រាក់ ១៧៥ ៣២២ ០០០ ០០០ រៀល**

**ប្រការ ២.**

ចំនួនទឹកប្រាក់អតិបរមាដែលអនុញ្ញាតទុកនៅបេឡាមានកំណត់ត្រឹមចំនួន ២ ០០០ ០០០៖០០ (ពីរលានរៀលគត់)។

**ប្រការ ៣.**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤.**

អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ ដូចមានចែងក្នុងប្រការ១ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល**

**ម៉ៅ.ហាវណ្ណាល់**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៦ សហវ. គ.ក.ក.

# សារាចរ
# ស្ដីពី
# ការបើកគណនីធនាគាររបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល អង្គភាពរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ និងសហគ្រាសសាធារណៈ

ក្នុងគោលបំណងធានាប្រក្រតីភាព និងសុវត្ថិភាពនៃប្រតិបត្តិការមូលនិធិគ្រប់ប្រភេទ ដែលគ្រប់គ្រងដោយក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល អង្គភាពរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ និងសហគ្រាសសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមធ្វើការណែនាំ ដូចខាងក្រោម៖

ក- ត្រូវបានអនុញ្ញាតឱ្យក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល អង្គភាពរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ និងសហគ្រាសសាធារណៈ បើកគណនីទៅតាមការចាំបាច់ជាគណនីចរន្តសម្រាប់ប្រតិបត្តិការចំណូល ឬ គណនីប្រាក់បញ្ញើគ្រប់ប្រភេទ ដើម្បីរក្សាមូលនិធិទាំងអស់របស់ខ្លួននៅធនាគារដែលបានកំណត់ ដូចខាងក្រោម៖

-គណនីចរន្តសម្រាប់ប្រតិបត្តិការចំណូលគ្រប់ប្រភេទ

-គណនីប្រាក់បញ្ញើគ្រប់ប្រភេទ ដែលរក្សាទុកមូលនិធិទាំងអស់ដែលគ្រប់គ្រងដោយស្ថាប័នរដ្ឋ។

ខ- ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល អង្គភាពរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ និងសហគ្រាសសាធារណៈ ដែលមានគណនីប្រាក់បញ្ញើនៅធនាគារពាណិជ្ជ មិនទាន់ផុតកាលកំណត់ ត្រូវបានអនុញ្ញាតឱ្យបន្តរហូតដល់ផុតកាលកំណត់។ បន្ទាប់ពីគណនីប្រាក់បញ្ញើនោះផុតកំណត់ហើយ ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល អង្គភាពរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ និងសហគ្រាសសាធារណៈ ត្រូវស្នើសុំការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អំពីការរក្សាទុកនៅធនាគារដដែល ឬ ផ្ទេរទៅធនាគារផ្សេង។

គ- ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល អង្គភាពរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ និងសហគ្រាសសាធារណៈ ដែលមានគណនីនៅធនាគារពាណិជ្ជ មិនទាន់ផុតកាលកំណត់ តែមានបំណងបញ្ចប់មុនកាលកំណត់ ឬ ផ្លាស់ប្តូរធនាគារ នោះការបើកគណនីប្រាក់បញ្ញើថ្មី ត្រូវស្នើសុំការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ឃ-រាល់ការបើកគណនីថ្មី រួមទាំងគណនីប្រាក់បញ្ញើមានកាលកំណត់របស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល អង្គភាពរដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

លើកលែងតែសហគ្រាសសាធារណៈ ត្រូវស្នើសុំការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ង. បន្ទាប់ពីបើកគណនីរួចរាល់ ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល អង្គភាពរដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ លើកលែងតែសហគ្រាសសាធារណៈ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ស្ដីពីឈ្មោះគណនី ឈ្មោះធនាគារ និងលេខគណនី មកអគ្គនាយកដ្ឋានរតនាគារជាតិ ឱ្យបានឆាប់រហ័ស។

ច- ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល អង្គភាពរដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ លើកលែងតែសហគ្រាសសាធារណៈ ត្រូវរៀបចំរបាយការណ៍ជាប្រចាំឆ្នាំ ស្ដីពីស្ថានភាពគណនីនៅធនាគារ មកអគ្គនាយកដ្ឋានរតនាគារជាតិ យ៉ាងយូរនៅចុងខែមករា នៅឆ្នាំបន្ទាប់។

ឆ- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិចាត់មន្ត្រីក្រោមឱវាទចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការបើកគណនីធនាគាររបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល អង្គភាពរដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ។

ទទួលបានសារាចរនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍អំពីលទ្ធផលនៃការអនុវត្តមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុវិញ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែចេត្រ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរជំនាញរាជធានី ខេត្ត
- គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ
- សហគ្រាសសាធារណៈ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**
លេខ: ០៦០៦ សក.សសរ

ទីស្តីការគណៈរដ្ឋមន្ត្រី
ចូល
លេខ 3895
ថ្ងៃទី 03 ខែ 08 ឆ្នាំ 26
ម៉ោង 3H08

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារសម្រាប់អនុវត្តអនុស្សរណៈនៃការយោគយល់គ្នា រវាងក្រសួងសាធារណការនិងដឹកជញ្ជូននៃព្រះរាជាណាចក្រកម្ពុជា និង ក្រសួងដឹកជញ្ជូននៃសហព័ន្ធរុស្ស៊ី ស្តីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យដឹកជញ្ជូន

## រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២២០ អនក្រ.បក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដំឡើងនាយកដ្ឋានសំណង់ប្រព័ន្ធចម្រោះទឹកកខ្វក់ ទៅជាអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១ ស្តីពីការប្រែក្លាយ និងដំឡើងវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសសាធារណការ និងដឹកជញ្ជូន ទៅជាវិទ្យាស្ថានតេជោសែនសាធារណការ និងដឹកជញ្ជូន របស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការដំឡើងនាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ ទៅជាអគ្គនាយកដ្ឋានបច្ចេកវិទ្យា និងទំនាក់ទំនងសាធារណៈ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ./.

- យោងអនុស្សរណៈនៃការយោគយល់គ្នា រវាងក្រសួងសាធារណការ និងដឹកជញ្ជូននៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងដឹកជញ្ជូននៃសហព័ន្ធរុស្ស៊ី ស្ដីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យដឹកជញ្ជូន ដែលបានចុះហត្ថលេខានៅថ្ងៃទី១ ខែមេសា ឆ្នាំ២០២៦ នៅទីក្រុងសាំងពីទែរប៊ួក សហព័ន្ធរុស្ស៊ី
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារសម្រាប់អនុវត្តអនុស្សរណៈនៃការយោគយល់គ្នា រវាងក្រសួងសាធារណការ និងដឹកជញ្ជូននៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងដឹកជញ្ជូននៃសហព័ន្ធរុស្ស៊ី ស្ដីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យដឹកជញ្ជូន ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ឡេង ធនយុទ្ធា** | រដ្ឋលេខាធិការ | ប្រធាន |
| ២. | ឯកឧត្តម **អ៊ាស៊ឹម សុរិយា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. | ឯកឧត្តម **កែន រដ្ឋា** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. | ឯកឧត្តម **ហេង រត្នពិសិដ្ឋ** | អគ្គនាយកសាធារណការ | សមាជិក |
| ៥. | តំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | | សមាជិក |
| ៦. | លោក **បូរាណា សត្យា** | អគ្គនាយករងដឹកជញ្ជូនផ្លូវគោក | សមាជិក |
| ៧. | លោក **សុខ សុផារ៉ា** | អគ្គនាយករងដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ | សមាជិក |
| ៨. | លោក **គីត ច័ន្ទដារ៉ារិទ្ធ** | អគ្គនាយករងភស្តុភារកម្ម | សមាជិក |
| ៩. | លោក **ថោង ទីរ៉ូ** | អគ្គនាយករងរដ្ឋបាល-គ្រប់គ្រង នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ | សមាជិក |
| ១០. | លោក **ខិន សុវណ្ណរតនៈ** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១១. | លោក **ម៉ែន ប៊ុណ្ណី** | អគ្គនាយករងមន្ទីរពិសោធន៍សំណង់ និងសាធារណការ | សមាជិក |
| ១២. | លោក **នីន និត្យា** | អនុប្រធាននាយកដ្ឋានពិនិត្យ តាមដាន និងវាយតម្លៃ | សមាជិក |
| ១៣. | លោក **សំ សុតី** | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ | សមាជិក |
| ១៤. | លោក **ទ្រៃ ប៊ុនលី** | អនុប្រធាននាយកដ្ឋានផ្លូវដែក | សមាជិក |
| ១៥. | លោក **ស វឌ្ឍនៈ** | ប្រធានការិយាល័យនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក។ |

**ប្រការ២.-**

ក្រុមការងារនេះ មានភារកិច្ច និងការទទួលខុសត្រូវ រួមមានដូចជា៖

- ប្រឹក្សា ពិគ្រោះយោបល់ និងលើកជាអនុសាសន៍ សំណើ សកម្មភាព ឬគំនិតផ្ដួចផ្ដើមនានាពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យដឹកជញ្ជូន ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនកិច្ចសហប្រតិបត្តិការបច្ចេកទេស និងការផ្លាស់ប្តូរបទពិសោធន៍ តាមរយៈការបណ្តុះបណ្តាល និងដំណើរទស្សនកិច្ចសិក្សានានា ដែលនឹងពង្រឹងកិច្ចសហប្រតិបត្តិការ រវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី
- ធ្វើការទំនាក់ទំនង ផ្លាស់ប្តូរទិន្នន័យ-ព័ត៌មានជាមួយក្រុមការងាររបស់ភាគីរុស្ស៊ី ដើម្បីរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យដឹកជញ្ជូនឱ្យមានសង្គតិភាព ប្រសិទ្ធភាព និងអាចទទួលយកបានដោយភាគីកម្ពុជា-រុស្ស៊ី ស្របតាមចក្ខុវិស័យរបស់ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ

- ទទួលបន្ទុករៀបចំកិច្ចប្រជុំក្រុមការងាររួមកម្ពុជា-រុស្ស៊ី ក្នុងឱកាសកម្ពុជាផ្លាស់ប្តូរវេនជាម្ចាស់ផ្ទះ
- លើកសំណើសមាសភាព និងដឹកនាំប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំក្រុមការងាររួមកម្ពុជា-រុស្ស៊ី ក្នុងឱកាសភាគីរុស្ស៊ីផ្លាស់ប្តូរវេនជាម្ចាស់ផ្ទះ
- រៀបចំសំណើវគ្គបណ្តុះបណ្តាល សន្និសីទ និងសិក្ខាសាលា ពាក់ព័ន្ធនឹងការងារអាទិភាពក្នុងវិស័យដឹកជញ្ជូនទៅកាន់ភាគីរុស្ស៊ី
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលការងារជូនរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ពាក់ព័ន្ធនឹងការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យដឹកជញ្ជូននេះជាមួយភាគីរុស្ស៊ី ដើម្បីគោរពស្នើសុំអនុសាសន៍ណែនាំ និងការសម្រេច
- បំពេញភារកិច្ចផ្សេងទៀតតាមការណែនាំរបស់ប្រធានស្ថាប័ន។

**ប្រការ៣.-**

ក្រុមការងារនេះត្រូវរៀបចំរបបប្រជុំផ្ទៃក្នុងរបស់ខ្លួនឱ្យបានទៀងទាត់ យ៉ាងហោចណាស់ ១ដង/១ឆ្នាំ ដើម្បីបូកសរុបវឌ្ឍនភាពការងារនៃការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យដឹកជញ្ជូន សម្រាប់ជួបប្រជុំជាមួយភាគីរុស្ស៊ី។

អនុប្រធាន និងសមាជិកនៃក្រុមការងារនេះ ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញ និងអនុវត្តភារកិច្ចតាមការប្រគល់ជូនរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ឬករណីចាំបាច់ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានដឹកនាំកិច្ចប្រជុំជំនួស។

ក្រុមការងារនេះ មានសិទ្ធិអញ្ជើញមន្ត្រីជំនាញ និងភាគីពាក់ព័ន្ធផ្សេងទៀត ចូលរួមកិច្ចប្រជុំ និងផ្តល់យោបល់ តាមការចាំបាច់។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថានតេជោសែនសាធារណការ និងដឹកជញ្ជូន ប្រធាននាយកដ្ឋាន ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត និងប្រធានអង្គភាពក្រោមឱវាទក្រសួង ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ១៥កើត ខែ [illegible] ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០២៦

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ប៉េង ពោធិ៍នា**

<u>កន្លែងទទួល៖</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងពាណិជ្ជកម្ម
- រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ..........................................

ថ្ងៃ.................ខែ............ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី............ ខែ............ ឆ្នាំ២០២៦

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៦ របស់ក្រុមហ៊ុន វី.អិន.ធី.អាយ ព្រីនធីង ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន **វី.អិន.ធី.អាយ ព្រីនធីង ឯ.ក (V.N.T.I PRINTING CO., LTD.)** តំណាងដោយលោក **LIU, JIAXIONG** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ **PE2083023** ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣ បង្កើតរោងចក្របោះពុម្ពគ្រប់ប្រភេទ ដែលមានទីតាំងស្ថិតនៅផ្លូវលេខ១០៥K ភូមិក្បាលដំរី២ សង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| បោះពុម្ពគ្រប់ប្រភេទ | ១៨១១ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្របោះពុម្ពគ្រប់ប្រភេទ វី.អិន.ធី.អាយ ព្រីនធីង ឯ.ក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបាន ឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការ របស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ៥២៤ ឧវបន.កឧ.ប្រក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ និងលិខិតលេខ២៦០៧ ឧវបន.កឧ.លស ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៤ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ចម្លងជូន៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងបរិស្ថាន
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -រាជកិច្ច
- -ខុទ្ទកាល័យរដ្ឋមន្ត្រី
- -សាលារាជធានីភ្នំពេញ
- -មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

បណ្ឌិត ធីង ស៊ីនី

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងបណ្ណសារជាតិ
ទីស្ដីការគណៈរដ្ឋមន្ត្រី